ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក ស្វាយទាប
ឃុំ គោកព្រីង
លេខ០០៤..ស.ជ.ណ

ថ្ងៃទី២៤.ខែ.តុលា.ឆ្នាំ២០០៦

# សេចក្តីជូនដំណឹង

## មេឃុំគោកព្រីង

សូមគោរពជំរាបជូនបងប្អូនប្រជាពលរដ្ឋរស់នៅក្នុងឃុំគោកព្រីងទាំងមូល ឱ្យបានជ្រាបថាដោយៈ

-យោងទៅលើស្មារតីដែលរៀបចំឡើងដោយសមាគមន៍ ភូមិសុខសាន្ត ស្តីពីការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ។

-យោងទៅតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាឃុំ ចុះថ្ងៃទី១៧.ខែតុលា.ឆ្នាំ២០០៦ដូចនេះក្នុងនាមជាមេឃុំសូមជូនដំណឹងដូចតទៅ :

១.មិនអនុញ្ញាតឱ្យជនណាម្នាក់ទទួលទានគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងវត្តជាដាច់ខាត

២.មិនអនុញ្ញាតឱ្យជនណាម្នាក់លើកតាំងផ្សាយពាណិជ្ជកម្មស្តីពីការលក់ស្រា និងគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលមានចម្ងាយតិចជាង ២០០ ម៉ែត ពីរបងវត្តឡើយ ។

ម៉្យាងទៀតដោយយល់ឃើញថាកុមារ កុមារី យុវជន យុវនារី ជាអ្នកស្នងអនាគតរបស់ប្រទេសជាតិនោះ សូមកុំបង្ខំ ឬ ឱ្យយុវជន យុវនារី ដែលមានអាយុក្រោម១៦ឆ្នាំ ទទួលទានសុរា ឬគ្រឿងស្រវឹងផ្សេងៗទៀត ហើយគួរតែកុំប្រើក្មេងអាយុក្រោម ១៦ឆ្នាំ ឱ្យទៅទិញស្រាដែរ និងអ្នកលក់ក៏គួរតែកុំលក់ស្រាឱ្យអ្នកទិញណាដែលមានអាយុក្រោម ១៦ឆ្នាំដែរ ។

មេឃុំគោកព្រីង

ចេត_សោមុនី